00590426

លេខ/No: D384/4

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Chambres Extraordinaires au sein des Tribunaux Cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត

Office of the Co-Investigating Judges

Bureau des Co-juges d'instruction

សំណុំរឿងព្រហ្មទណ្ឌ

Criminal Case File /Dossier pénal

លេខ/No: 002/14-08-2006

លេខស៊ើបសួរ/Investigation/Instruction

លេខ/No: 002/19-09-2007-ECCC-OCIJ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Royaume du Cambodge

Nation Religion Roi

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

CERTIFIED COPY/COPIE CERTIFIÉE CONFORME

ថ្ងៃ ខែ ឆ្នាំ ធ្វើការបញ្ជាក់ (Certified Date /Date de certification): 17-Aug-2010, 15:42

Kauv Keoratanak

# សៀវភៅចុះបញ្ជីឧទ្ធរណ៍

# Record of Appeals

# Registre des appels

ឆ្នាំពីរពាន់ដប់ ខែសីហា ថ្ងៃទីដប់ប្រាំមួយ វេលាម៉ោងដប់ប្រាំនិងសាមសិបនាទីរសៀល

យើង លីច័ន្ទតុលា និង ហាម ហ៊ៃល ក្រឡាបញ្ជីនៃសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញ

បានទទួលពាក្យបណ្តឹងឧទ្ធរណ៍របស់លោកមេធាវី Michiel PESTMAN និង Victor KOPPE

ជាសហមេធាវីរបស់ជនត្រូវចោទ នួនជា

សុំប្តឹងឧទ្ធរណ៍នឹងការបដិសេធតាមការសន្មតចំពោះសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី២របស់មេធាវីនួនជា

(វិធាន ៣៥) ចុះថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០១០ ដែលត្រូវបានជូនដំណឹងនៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១០។

ឯកសារដើម

ORIGINAL DOCUMENT/DOCUMENT ORIGINAL

ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 17 / 08 / 2010

ម៉ោង (Time/Heure): 15:30

មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

ក្រឡាបញ្ជី

Greffiers

LY Chantola

00590427

D384/4

# នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក នួន ជា

ដាក់ជូន: ការិយាល័យសហចៅក្រមស៊ើបអង្កេត

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 16 / 08 / 2010
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គបុរេជំនុំជម្រះ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## សេចក្ដីជូនដំណឹងពីបណ្ដឹងឧទ្ធរណ៍

---

**ដាក់ដោយ៖**

**សហមេធាវីរបស់លោក នួន ជា**

លោក Michiel PESTMAN

លោក Victor KOPPE

លោក Andrew IANUZZI

លោក Jasper PAUW

កញ្ញា Oyinlola OGUNTEBI (កម្មសិក្សាការីច្បាប់)

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្ដីទាំងអស់**

D 384/4

# សេចក្តីជូនដំណឹងពីបណ្តឹងឧទ្ធរណ៍

1. មេធាវីការពារជនត្រូវចោទ **នួន ជា** ("ហៅថាមេធាវីការពារ") សូមដាក់នូវសេចក្តីជូនដំណឹងពីបណ្តឹងឧទ្ធរណ៍ជូនការិយាល័យសហចៅក្រមស៊ើបអង្កេត("កសចស") ដោយអនុលោមតាម (១) សាលដីការលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ទាក់ទងនឹងការចាត់តាំងអ្នកជំនាញផ្នែកចិត្តសាស្ត្រ ("សាលដីកា")[1] និង (២) វិធាន ៣៥(៦) នៃវិធានផ្ទៃក្នុងរបស់ អវតក ("វិធាន")។

2. កាលពីថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១០ មេធាវីការពារក្តីបានដាក់ "សំណើលើកទី២ សុំបំពេញកិច្ចស៊ើបសួរ("សំណើលើកទី២")[2]។ មេធាវីការពារក្តីបានផ្ញើលិខិតជូន កសចស ទាក់ទងនឹង សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី២ ("លិខិតជូន កសចស")[3] នៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១០ តែមិនបានទទួលសេចក្តីសម្រេចណាមួយលើសំណើលើកទី២ ពី កសចស នៅឡើយទេ។ លិខិតជូន កសចស បានស្នើឲ្យ កសចស ចេញសេចក្តីសម្រេចលើសំណើលើកទី២ នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១០ ដើម្បីផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់មេធាវីការពារក្តីដាក់បណ្តឹងឧទ្ធរណ៍ ប្រសិនបើ កសចស បដិសេធលើសំណើ ដោយផ្នែក ឬទាំងស្រុង[4]។ លិខិតជូន កសចស បានកត់សម្គាល់ថា ប្រសិនបើ មេធាវីការពារក្តីមិនបានទទួលការឆ្លើយតបនៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១០ នោះមេធា

---

[1] ឯកសារ A-189/I/8, ថ្ងៃទី ២១ ខែតុលា ឆ្នាំ២០០៨, កថាខ័ណ្ឌ24 ("ការខកខានរបស់សហចៅក្រមស៊ើបអង្កេតក្នុងការចេញសេចក្តីសម្រេចលើសំណើសុំឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ក្នុងកាលៈទេសៈដែលថា ការពន្យារនៃការចេញសេចក្តីសម្រេចនេះធ្វើឲ្យជនត្រូវចោទបាត់បង់លទ្ធភាពទទួលបានផលប្រយោជន៍ដែលខ្លួនចង់បាន ការខកខានបែបនេះបង្កើតជាការបដិសេធតាមការសន្មតលើសំណើសុំ ដែលការបដិសេធបែបនេះ បើកផ្លូវឲ្យប្តឹងឧទ្ធរណ៍បាន").

[2] ឯកសារ D-384, ថ្ងៃ០៧ ខែកក្កដា ឆ្នាំ២០១០, ERN 00549028-00549031 (សំណើលើកទី២)។

[3] ឯកសារលេខ D-384/2 "លិខិតជូន កសចស, កម្មវត្ថុ: មិនមានការឆ្លើយតបនឹងសំណើលើវិធាន៣៥" ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១០ ERN 00581379-00581380។

[4] លិខិតជូន កសចស ទំព័រទី២។ មេធាវីការពារក្តីធ្លាប់បានសុំ កសចស ឲ្យសម្រេចលើសំណើលើកទី២ "ក្នុងរយៈពេលមួយសប្តាហ៍ គិតចាប់ពីថ្ងៃដាក់លិខិត", ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១០, "វេលាគ្រប់គ្រាន់ដើម្បីធ្វើបណ្តឹងឧទ្ធរណ៍មួយដ៏មានប្រសិទ្ធភាព នៅចំពោះមុខអង្គបុរេជំនុំជម្រះ មុនពេលការចេញដីកាដំណោះស្រាយ ប្រសិនបើសំណើត្រូវបានបដិសេធដោយផ្នែក ឬទាំងស្រុង"។ សំណើលើកទី២ កថាខណ្ឌ៩(ខ)។

វីការពារក្តី នឹងគិតថា ភាពស្ងៀមស្ងាត់របស់ កសចស បង្កើតបានជាការបដិសេធតាមការសន្មត លើសំណើលើកទី២ និងបន្ទាប់មកទៀត នឹងដាក់បណ្តឹងឧទ្ធរណ៍នេះ[5]។

3. រហូតមកដល់ពេលនេះ មេធាវីការពារក្តីពុំបានទទួលសេចក្តីសម្រេចណាមួយពី កសចស នៅឡើយទេ។

4. អាស្រ័យហេតុនេះហើយ មេធាវីការពារបកស្រាយថា ការខកខានរបស់ កសចស ក្នុងការសម្រេចលើសំណើលើកទី២ ព្រមទាំងការង្ហាញដោយគ្មានឆន្ទៈក្នុងការបើកការស៊ើបអង្កេតឲ្យបានរហ័សថាជាការបដិសេធលើសំណើលើកទី២ ដូច្នេះនឹងប្រើប្រាស់សិទ្ធិប្តឹងឧទ្ធរណ៍របស់ខ្លួនដូចដែលបានផ្តល់ឲ្យនៅក្នុងសាលដីការរបស់អង្គបុរេជំនុំជម្រះ។

**សហមេធាវីរបស់លោក នួន ជា**

p.p.

Michiel PESTMAN — Victor KOPPE

[5] លិខិតជូន កសចស, ទំព័រ២។